# គម្រោងស្តីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

## រៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា

## វគ្គបណ្តុះបណ្តាលគ្រូមូលដ្ឋានលើកទី១៥ នៅខេត្តកោះកុង

## ៧-១២ កញ្ញា ២០១៤

មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា មានកិត្តិយសសូមប្រកាសនូវកម្មវិធីស្តីអំពីការបង្រៀន «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» លើកទី១៥ សម្រាប់គ្រូប្រវត្តិវិទ្យា ភូមិវិទ្យា ភាសាខ្មែរ និងសីលធម៌ពលរដ្ឋ ដែលនឹងប្រព្រឹត្តទៅនៅក្នុងបរិវេណវិទ្យាល័យកោះកុង ចាប់ពីថ្ងៃទី៧-១២ ខែកញ្ញា ឆ្នាំ២០១៤ ដើម្បីផ្តល់នូវខ្លឹមសារប្រវត្តិសាស្ត្រវិធីសាស្ត្រ ក៏ដូចជាសម្ភារៈឧបទ្ទេសដល់លោកគ្រូអ្នកគ្រូនៅខេត្តកោះកុង សម្រាប់ការអប់រំពីអំពើប្រល័យពូជសាសន៍នៅតាមថ្នាក់រៀន។ នេះគឺជាវគ្គបណ្តុះបណ្តាលគ្រូលើកដំបូងបង្អស់ ដែលមានការដាក់បញ្ចូលនូវជំពូកថ្មីមួយស្តីពីការជម្លៀសដោយបង្ខំ។ ជំពូកថ្មីនេះត្រូវបានរៀបចំឡើងតាមរយៈគម្រោងសំណុំរឿងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។

បន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ប្រទេសកម្ពុជានៅតែប្រឈមមុខនឹងផលវិបាកនៃអំពើប្រល័យពូជសាសន៍អស់រយៈពេល៣៥ឆ្នាំក្រោយមក។ កាលពីថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងនៃសាលាក្តីខ្មែរក្រហមរកឃើញថា អតីតមេដឹកនាំខ្មែរក្រហម២រូបគឺ នួន ជា និង ខៀវ សំផន មានពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ អ្នកទាំងពីរត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត។ ដោយហេតុនេះ អ.វ.ត.ក បានអនុម័តលើគម្រោងសំណង១១នៃគម្រោងសំណងទាំង១៣ ដែលបានស្នើសុំ។ ការដាក់បញ្ចូលជំពូកមួយស្តីពីការជម្លៀសដោយបង្ខំទៅក្នុងជំពូកទីបី នៃសៀវភៅណែនាំសម្រាប់គ្រូបង្រៀន បញ្ជាក់ពីប្រភេទសំណងមួយក្នុងចំណោមគម្រោងសំណងទាំង១១ ដែលត្រូវបានអនុម័ត។ ជំពូកនេះត្រូវបានរៀបចំឡើង ក្រោមការស្នើសុំរបស់មេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ដោយមានការចូលរួមពីផ្នែកគាំពារជនរងគ្រោះ។ ជំពូកថ្មីនេះនឹងត្រូវបង្រៀនជាលើកដំបូងបង្អស់ក្នុងវគ្គបណ្តុះបណ្តាលគ្រូមូលដ្ឋាន នៅខេត្តកោះកុង។

សព្វថ្ងៃនេះ ប្រទេសកម្ពុជាមើលឃើញអំពីសារៈសំខាន់នៃការអប់រំថា ជាវិធីសាស្ត្រដ៏ចាំបាច់មួយ ដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍ ព្យាបាលរបួសផ្លូវចិត្ត សន្តិភាព និងការផ្សះផ្សា។ ដើម្បីសម្រេចឲ្យបាននូវគោលដៅនេះ មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំវគ្គបណ្តុះបណ្តាលជាច្រើន។ ចាប់តាំងពីឆ្នាំ២០០៩មក លោកគ្រូអ្នកគ្រូជាង៣ពាន់នាក់

ដែលបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យា ភូមិវិទ្យា ភាសាខ្មែរ និងសីលធម៌ពលរដ្ឋនៅទូទាំងប្រទេស ទទួលបានការបណ្តុះបណ្តាលនេះ ។ ដើម្បីពង្រីកបន្ថែមនូវចំណេះដឹងអំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា ក៏បានអភិវឌ្ឍកម្មវិធីសិក្សា សម្រាប់ផ្នែកផ្សេងៗទៀតនៃក្នុងសង្គមស៊ីវិលនិងរាជរដ្ឋាភិបាល ។ សាស្ត្រាចារ្យសាកលវិទ្យាល័យ ដែលបង្រៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន មន្ត្រីប៉ូលិស មន្ត្រីទាហាន និងគរុនិស្សិតនៃវិទ្យាស្ថានជាតិអប់រំ ទទួលបានការបណ្តុះបណ្តាលអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងការបណ្តុះបណ្តាលទៅលើមុខវិជ្ជាជំនាញដាក់លាក់ផ្សេងៗទៀត ដែលទាក់ទងទៅនឹងអំពើប្រល័យពូជសាសន៍ ។ បន្ថែមពីលើការរីកចំរើនទាំងនេះ មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា នឹងចាប់ផ្តើមកម្មវិធីមួយបន្ថែមទៀត ដែលនឹងបណ្តុះបណ្តាលគរុសិស្ស នៅតាមមជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង៦ នៅក្នុងខេត្តតាកែវ កំពង់ចាម ព្រៃវែង កណ្តាល បាត់ដំបង និងរាជធានីភ្នំពេញ ។

ការយល់ដឹងអំពីអតីតកាលរបស់ខ្លួន ក៏ដូចជាការកែតម្រូវឥរិយាបទបុគ្គលនិងសីលធម៌ទូទៅ គឺមានសារៈសំខាន់ណាស់សម្រាប់មនុស្សគ្រប់គ្នា ជាពិសេសក្មេងៗជំនាន់ក្រោយក្នុងការចូលរួមដឹកនាំប្រទេសនាពេលអនាគត ។ ការយល់ដឹងទូលំទូលាយពីអំពើប្រល័យពូជសាសន៍នៅក្នុងរបបខ្មែរក្រហម និងប្រវត្តិនៃជម្លោះនៅក្នុងប្រទេសកម្ពុជា នឹងជួយជម្រុញឲ្យយុវជនជំនាន់ក្រោយ ក្លាយទៅជាកម្លាំងចលករសម្រាប់ការផ្លាស់ប្តូរ ។ ប្រទេសកម្ពុជាចាំបាច់ត្រូវអប់រំយុវជនជំនាន់ក្រោយ ឲ្យក្លាយទៅជាពលរដ្ឋប្រកបដោយចំណេះដឹង ដែលអាចចូលរួមចំណែកនៅក្នុងការកសាងសង្គមមួយប្រកបដោយយុត្តិធម៌ សមភាព និងសន្តិភាព ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកលោក ម៉ម សុវណ្ណ truthsovann@dccam.org
ទូរស័ព្ទ ៖ ០១២ ៨៨៣ ៨២៨
www.dccam.org l www.cambodiatribunal.org l www.cambodiasri.org

វគ្គបណ្តុះបណ្តាលទទួលបានជំនួយទ្រទ្រង់ពី វិទ្យាស្ថានសន្តិភាពសហរដ្ឋអាមេរិក (USIP) ។ ប្រតិបត្តិការគោលទទួលបានជំនួយទ្រទ្រង់ពី ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) (២០១៣-២០១៤)